**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៦០ **អយក.**សាសណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡាជំនាន់ទី២៩ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា សម្រាប់ឆ្នាំ២០១៩

យោង៖ លិខិតលេខ២៥៦០អយក.បល ចុះថ្ងៃ ព្រហស្បតិ៍ ១២រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងដល់មន្ត្រីរាជការ សិស្ស និស្សិតឱ្យបានជ្រាបថា៖ ក្រសួងនឹងរៀបចំប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡាចំនួន១៥០នាក់ ឱ្យចូលរៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ជំនាន់ទី២៩ សិក្សារយៈពេល២ឆ្នាំ ។

ក្នុងការជ្រើសរើសនេះក្រសួងអប់រំ យុវជន និងកីឡា បានកំណត់បែងចែកកន្លែងទៅបំពេញការងារតាមរាជធានី-ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម៖

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | ខេត្តស្ទឹងត្រែង | ចំនួន | ៣នាក់ | ២- | ខេត្តព្រះវិហារ | ចំនួន | ៥នាក់ |
| ៣- | ខេត្តរតនគិរី | ចំនួន | ២នាក់ | ៤- | ខេត្តកំពង់ឆ្នាំង | ចំនួន | ៧នាក់ |
| ៥- | ខេត្តកំពង់ស្ពឺ | ចំនួន | ២នាក់ | ៦- | ខេត្តបាត់ដំបង | ចំនួន | ១៨នាក់ |
| ៧- | ខេត្តពោធិ៍សាត់ | ចំនួន | ៧នាក់ | ៨- | ខេត្តបន្ទាយមានជ័យ | ចំនួន | ១១នាក់ |
| ៩- | ខេត្តសៀមរាប | ចំនួន | ២៧នាក់ | ១០- | ខេត្តឧត្តរមានជ័យ | ចំនួន | ៣នាក់ |
| ១១- | ខេត្តកំពង់ចាម | ចំនួន | ៩នាក់ | ១២- | ខេត្តត្បូងឃ្មុំ | ចំនួន | ១៦នាក់ |
| ១៣- | ខេត្តកំពង់ធំ | ចំនួន | ៨នាក់ | ១៤- | ខេត្តក្រចេះ | ចំនួន | ៦នាក់ |
| ១៥- | ខេត្តព្រៃវែង | ចំនួន | ១៨នាក់ | ១៦- | ខេត្តស្វាយរៀង | ចំនួន | ៩នាក់ |

**I-លក្ខខណ្ឌនៃការជ្រើសរើស៖**

១-បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ

២-បេក្ខជនទាំងពីរភេទត្រូវមានអាយុចាប់ពី១៧ឆ្នាំដល់២៥ឆ្នាំគិតត្រឹមថ្ងៃប្រឡង (ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩)

៣-បេក្ខជនទាំងពីរភេទត្រូវនៅលីវរហូតដល់បញ្ចប់ការបណ្តុះបណ្តាល



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

៤-បេក្ខជនទាំងពីរភេទត្រូវមានសុខភាពល្អ កាយសម្បទាមាំមួន និងគ្រប់លក្ខណៈ (ត្រូវពិនិត្យកាយសម្បទាមុនពេលប្រឡង) ទីតាំងពិនិត្យសុខភាពស្ថិតនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

**-បេក្ខជន៖ នារី** ត្រូវមានកម្ពស់ចាប់ពី ១,៥៥ម៉ែត្រ ឡើងទៅ

**-បេក្ខជន៖ ប្រុស** ត្រូវមានកម្ពស់ចាប់ពី ១,៦៥ម៉ែត្រ ឡើងទៅ

៥-បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ។

**II-លក្ខខណ្ឌនៃការដាក់ពាក្យសុំប្រឡង៖**

១-បេក្ខជន ត្រូវជ្រើសរើសយក អនុវិទ្យាល័យ ឬ វិទ្យាល័យ តែមួយ ដែលមានឈ្មោះតម្រូវការគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡារបស់រាជធានី- ខេត្តនោះ ហើយត្រូវសរសេរលើសំណុំលិខិតអំណះអំណាងរបស់បេក្ខជន

២-សំណុំលិខិតអំណះអំណាងរបស់បេក្ខជននេះ ត្រូវមានចំណាររយល់ព្រមរបស់នាយក / នាយិកា ឬគណៈគ្រប់គ្រង អនុវិទ្យាល័យ ឬវិទ្យាល័យ របស់រាជធានី-ខេត្តនោះ

៣-បេក្ខជនត្រូវធ្វើកិច្ចសន្យា បំពេញការងារនៅ អនុវិទ្យាល័យ ឬ វិទ្យាល័យ របស់រាជធានី-ខេត្តនោះ ទុកពេលបញ្ចប់ការបណ្តុះបណ្តាលជាស្ថាពរ ។

៤-សំណុំលិខិតអំណះអំណាង និងកិច្ចសន្យារបស់បេក្ខជន ទុកជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាពិនិត្យសម្រេចលើលទ្ធផលប្រឡងជ្រើសរើស សម្រាប់ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ។

**បញ្ជាក់៖** ក្រោយពីប្រឡងបញ្ចប់ការបណ្តុះបណ្តាលជាប់ជាស្ថាពរ គរុសិស្សត្រូវបានទទួលក្របខ័ណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡា ។ ហើយក្នុងករណីគរុសិស្សមិនទៅបម្រើការងារ តាមកន្លែងដែលបានជ្រើសរើសយក និងបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានោះទេ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីក្របខណ្ឌ ។

**III-សំណុំលិខិតដែលត្រូវបំពេញមាន៖**

១-សញ្ញាបត្រ ឬវិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាទុតិយភូមិ ច្បាប់ថតចម្លង ០១សន្លឹក មានបញ្ជាក់និត្យានុកូលកម្មពីសាលារាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវសញ្ញាបត្រច្បាប់ដើមមកជាមួយផង (ចំពោះសិស្សជាប់សញ្ញាបត្រមុនឆ្នាំសិក្សា២០១៨-២០១៩)

ចំពោះសិស្សទើបប្រឡងជាប់សញ្ញាបត្រឆ្នាំសិក្សា២០១៨-២០១៩ ត្រូវភ្ជាប់មកជាមួយនូវព្រឹត្តិប័ត្រពិន្ទុដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ច្បាប់ដើមចំនួនមួយសន្លឹក

| | |
|---|---|
| ២-ជីវប្រវត្តិសង្ខេប(មានបិទរូបថតថ្មី) | ចំនួន០១ច្បាប់ |
| ៣-លិខិតបញ្ជាក់កិរិយាមាយាទ | ចំនួន០១ច្បាប់ |
| ៤-រូបថត៤×៦(ថតថ្មីចំពីមុខគ្មានពាក់មួក ឬវ៉ែនតា) | ចំនួន០៣សន្លឹក |
| ៥-បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន០១ច្បាប់ |
| ៦-សលាកប័ត្រឯកត្តជន(មានបិទរូបថតថ្មី) | ចំនួន០២ច្បាប់ |
| ៧-លិខិតធានារបស់ឪពុក ម្តាយ ឬអាណាព្យាបាល | ចំនួន០១ច្បាប់ |

៨-កិច្ចសន្យា ចំនួន០១ច្បាប់

៩-លិខិតបញ្ជាក់សុខភាព និងកាយសម្បទា ចំនួន០១ច្បាប់

១០-លិខិតអំណះអំណាងរបស់បេក្ខជន ចំនួន០១ច្បាប់

IV- **កន្លែងទទួលពាក្យប្រឡង៖**

១-នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលមានទីតាំងនៅផ្លូវលេខ៥៩៨ ភូមិល្វ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ

២-នៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តទាំង១៦ ដែលទទួលបានការបែកចែងក្របខណ្ឌប្រឡងជ្រើសរើស ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា

**បញ្ជាក់៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្តទាំង១៦ ត្រូវបញ្ជូនសំណុំលិខិតរបស់បេក្ខជនបានដាក់ពាក្យប្រឡងទាំងអស់ មកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាត្រឹមថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៧:០០នាទីរសៀលជាកាលកំណត់។

៣-កាលបរិច្ឆេទនៃការទទួលពាក្យចុះឈ្មោះប្រឡងចាប់ពីថ្ងៃប្រកាសផ្សាយជូនដំណឹងនេះរហូតដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៧:០០នាទីរសៀល

-ចំពោះព័ត៌មានផ្សេងៗ សូមទំនាក់ទំនងផ្ទាល់នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា រៀងរាល់ម៉ោងធ្វើការ ។

**កំណត់សម្គាល់៖**

-បេក្ខជនអាចទាញយកសំណុំលិខិតសុំចុះឈ្មោះប្រឡងពីគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា WWW.moeys.gov.kh និងនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

III-**កាលបរិច្ឆេទប្រឡង មណ្ឌលប្រឡង និងវិញ្ញាសាប្រឡង៖**

១-**កាលបរិច្ឆេទប្រឡង៖** ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៩ ប្រឡងវិញ្ញាសា: សរសេរ និង
ថ្ងៃបន្តបន្ទាប់ ប្រឡងវិញ្ញាសា: អនុវត្តន៍កីឡា

២-**មណ្ឌលប្រឡង ៖**

-មណ្ឌលប្រឡងវិញ្ញាសាសរសេរ៖ **នៅវិទ្យាល័យជាស៊ីមសន្ធរម៉ុក**

-មណ្ឌលប្រឡងវិញ្ញាសាអនុវត្តន៍កីឡា៖ **នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា**

៣-**វិញ្ញាសាប្រឡង៖**

ក-វិញ្ញាសាសរសេរ ៖ កម្មវិធីថ្នាក់ទី១២

១-វប្បធម៌ទូទៅ ៖ រយៈពេល ២ ម៉ោង

២-ជីវវិទ្យា ៖ រយៈពេល ១ ម៉ោង ៣០នាទី

ខ-វិញ្ញាសាអនុវត្តន៍កីឡា

១-កីឡាអត្តពលកម្ម៖

-រត់ល្បឿន ចម្ងាយ៨០ម៉ែត្រ(នារី) និងចម្ងាយ១០០ម៉ែត្រ(បុរស)

-លោតចម្ងាយ (នារី -បុរស)

-ចោលដុំដែកទម្ងន់៣គីឡូក្រាម(នារី)   និងទម្ងន់៥គីឡូក្រាម(បុរស)

២-កីឡារួមៈ **សម្រាប់បុរស និងសម្រាប់នារី មានៈ**

-បាល់ទះ ៖ ការវាយសេវា ការបញ្ជូនបាល់សំដៅរង្វង់កង ការវាយ(ឬគប់)បាល់

-បាល់បោះ ៖ ការបញ្ជូនបាល់ ការបណ្ដើរបាល់ ស៊ុតបាល់ពិន័យ ការរត់ដាក់បាល់

-បាល់ទាត់ ៖ បញ្ជូនបាល់បញ្ចូលទីដោយប្រអប់ជើង ទទួលបាល់ដោយផ្ទៃសារពាង្គកាយ និងបណ្ដើរបាល់តាមចន្លោះទង់

**កំណត់សម្គាល់៖**

-ចាប់ពីប្រកាសលទ្ធផលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវមកដាក់ពាក្យសុំចូលរៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា រហូតដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១៧:០០នាទីរសៀល ជាការកំណត់ចុងក្រោយ

-កាលបរិច្ឆេទចូលរៀនថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

-ក្នុងករណីបេក្ខជនមិនមកដាក់ពាក្យចូលរៀន ហួសរយៈពេល១០ថ្ងៃនៃកាលបរិច្ឆេទចូលរៀនវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា រក្សាសិទ្ធិក្នុងការស្នើសុំលុបឈ្មោះ និងស្នើសុំជ្រើសរើសបេក្ខជនជាប់បម្រុងមកជំនួសតាមលំដាប់នៃចំណាត់ថ្នាក់ជាបន្តបន្ទាប់ ។

**បញ្ជាក់៖** បេក្ខជនដែលបានប្រឡងជាប់ ទទួលបានចំណាត់ថ្នាក់ពីលេខ១ ដល់លេខ២៥ ចំនួន២៥នាក់ ត្រូវបានជ្រើសរើសឱ្យរៀនកម្រិតបរិញ្ញាបត្រ រយៈពេល៤ឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ។ ក្នុងករណីបេក្ខជនណាម្នាក់មិនចង់ជ្រើសយកការសិក្សាបរិញ្ញាបត្រ រយៈពេល៤ឆ្នាំ បេក្ខជនលេខរៀងបន្ទាប់នឹងចូលមកជំនួស។

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ចម្លងជូនៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
"ដើម្បីជូនជ្រាបជាព័តមាន"
-គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី.ខេត្ត
-គ្រប់អង្គភាពក្រោមឱវាទ ក្រសួងអប់រំ យុវជន និងកីឡា
"ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ"
-កាលប្បវត្តិ
-ឯកសារ.រអក